ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ០៤

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC

កសវ



Work Activities

ប្រចាំខែមេសា ឆ្នាំ២០១៤



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីវប្បធម៌ជាតិ | ១ |
| ២- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមីនា ឆ្នាំ២០១៤ | ៤ |
| ៣- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

# សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីវប្បធម៌ជាតិ

កាលពីថ្ងៃទី២៥និងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ នៅទីស្ដីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្ដម ឆយ អូន សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្ដម លឹម សំអាត សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីវប្បធម៌ជាតិ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី សុខ អាន មន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។



បេតិកភណ្ឌវប្បធម៌ដ៏សម្បូរណ៍បែប ទាំងរូបី និងអរូបី ដែលបុព្វបុរសយើងបានបន្សល់ទុករហូតដល់សព្វថ្ងៃ មិនត្រឹមតែជាសក្ខីភាពបង្ហាញពីភាពរុងរឿងថ្កុំថ្កើង គួរជាទីស្ញប់ស្ញែងនៃមនុស្សជាតិប៉ុណ្ណោះទេ ថែមទាំងមានតួនាទីដ៏សំខាន់ក្នុងការផ្សារភ្ជាប់នូវទំនាក់ទំនងរវាងមនុស្សនិងមនុស្ស សង្គមនិងសង្គម ព្រមទាំងរួមចំណែកក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពទៀតផង។ ក៏ប៉ុន្តែ ក្នុងចរន្តនៃសាកលភាវូបនីយកម្ម សម័យបច្ចេកវិទ្យាទំនើបបានញ៉ាំងឲ្យសង្គមមានការវិវត្តយ៉ាងគំហុក ដែលជាហេតុធ្វើឲ្យមរតកវប្បធម៌ដ៏មានតម្លៃ ជាពិសេសបេតិកភណ្ឌវប្បធម៌អរូបី ទទួលរងនូវការប្រឈមយ៉ាងខ្លាំងរហូតដល់អាចនឹងឈានដល់បាត់បង់ដោយអន្លើៗ។

អាស្រ័យហេតុនេះ ដើម្បីប្រសិទ្ធភាព និងប្រសិទ្ធផលដល់ការចូលរួមថែរក្សា ការពារ អភិរក្សបេតិកភណ្ឌវប្បធម៌ជាតិឲ្យបានគង់វង្ស និងការចូលរួមគាំទ្រឲ្យមានការវិនិយោគលើវិស័យវប្បធម៌ ដើម្បីកំណើនសេដ្ឋកិច្ច ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយមានការគាំទ្រពីអង្គការយូណេស្កូ (UNESCO) បានរៀបចំសេចក្ដីព្រាងគោលនយោបាយជាតិលើវិស័យវប្បធម៌ ដើម្បីជាត្រីវិស័យសម្រាប់បេសកកម្មការងាររបស់ខ្លួន។



គោលនយោបាយជាតិលើវិស័យវប្បធម៌នេះ ត្រូវបានរៀបចំឡើងដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងមានការគាំទ្រពីអង្គការ UNESCO ព្រមទាំងបានដាក់ឲ្យធ្វើការពិគ្រោះយោបល់ក្នុងសិក្ខាសាលាស្តីពី ការកសាងសមត្ថភាពយល់ដឹងលើការអភិវឌ្ឍវប្បធម៌ ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ នៅភ្នំពេញ។

គោលនយោបាយជាតិនេះមានចក្ខុវិស័យ អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ លើកកម្ពស់សីលធម៌ គុណធម៌ប្រពៃណីជាតិ និងពង្រឹងអត្តសញ្ញាណ កិត្យានុភាពជាតិ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម[១]។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងគោលនយោបាយជាតិស្តីពីវប្បធម៌ជាតិ។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃពុធ ទី០៩ ខែមេសា ឆ្នាំ២០១៤ នៅវេលាម៉ោង ៩:០០នាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី សុខ អាន សាមីក្រសួង និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើ៖

១- សេចក្តីព្រាងច្បាប់ ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ

៣- បញ្ហាផ្សេងៗ

៣.១-សទ្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៣.២-កិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមក ផ្នែកយុត្តិធម៌ក្នុងវិស័យរដ្ឋប្បវេណីរវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

### ១-សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

អង្គប្រជុំបានសម្រេចឲ្យ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អញ្ជើញតំណាងក្រសួងកសិកម្ម



រុក្ខាប្រមាញ់ និងនេសាទ តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម តំណាងក្រសួងពាណិជ្ជកម្ម និងតំណាងក្រសួងសុខាភិបាល ដើម្បីធ្វើការប្រជុំពិភាក្សាសម្របសម្រួលការជាន់ភារកិច្ចគ្នា នៃសេចក្តីព្រាងច្បាប់នេះ មុនពេលដាក់ប្រជុំត្រួតពិនិត្យចុងក្រោយសារជាថ្មី។

អង្គប្រជុំបានបិទសម័យប្រជុំរបស់ខ្លួន ដោយស្មាគីឯកភាពទទួលខុសត្រូវខ្ពស់។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមីនា ឆ្នាំ២០១៤*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និវប្បធម៌កម្ពុជា**ប្រចាំខែមីនា ឆ្នាំ២០១៤**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី06 ខែឧសភា ឆ្នាំ២០១៤ ដែលដឹកនាំដោយឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្រ្តីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិកសមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមីនា ឆ្នាំ២០១៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង 0,៥% ធៀបនឹងខែមុន និងកើនឡើង ៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។ ការឡើងថ្លៃទំនិញប្រើប្រាស់នេះ ជារួមបណ្តាលមកពីក្រុមម្ហូបអាហារ គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ សុខាភិបាល ការសិក្សា និងភោជនីយដ្ឋាន ។

តារាង១.១ .បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុន សម្រាប់ក្រុមទំនិញនិងមុខទំនិញសំខាន់ៗ

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ម្ហូបអាហារ : | +៦,២% | សាច់ជ្រូក : | +៨,១% |
| សម្លៀកបំពាក់និងស្បែកជើង : | +៤,៥% | សាច់គោស្រស់ : | +៨,២% |
| ផ្ទះសំបែង ទឹក អគ្គិសនី : | +២,៧% | សាច់មាន់ស្រស់ : | +៧,៦% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ : | +៩,២% | ត្រីស្រស់ : | +៧,១% |
| សុខាភិបាល : | +៨,៨% | ផ្លែឈើ : | +១១,១% |
| ការដឹកជញ្ជូន : | -0,៧% | បន្លែ : | +២,៧% |
| ទូរគមនាគមន៍ : | -២,៣% | ឧស្ម័ន : | +៣,៦% |
| ការកម្សាន្តនិងវប្បធម៌ : | +៤,៦% | ប្រេងសាំង : | -៣,៦% |
| ការសិក្សា : | +៩,៥% | ប្រេងម៉ាស៊ូត : | -0,៤% |
| ភោជនីយដ្ឋាន : | +៨,៤% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង១.២បម្រែបម្រួល .សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១២–២០១៤

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មិនា | មេសា[P] | ឧសភា[P] | មិថុនា[P] | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤៥%, | ៤,៣% | ៥,០% | ៤,៨% | ៤,៩% | ៥,០% | | | | | | | |
| | មុន | ០២,% | ០ | ០,៥% | ០,៤% | ០៨,% | ០៣,% | | | | | | | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១៨%, | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣០%, |
| | មុន | ០៣,% | ០,២% | ០-,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០២%, | -០,៣% | ០,៥% | |
| ២០១២ | ដូចគ្នាឆ្នាំមុន | ៥៨%, | ៥៤%, | ៥៤%, | ៤៨%, | ២២%, | ១៨%, | ១៣%, | ២,២% | ១,៤% | ១,២% | ១,៦% | ២៦%, | ២,៩% |
| | មុន | ១០,% | ០៤,% | ០៦%, | ០៥%, | -១១%, | ០១%, | ០% | ១,១% | ០,២% | ០-,២% | ០-,២% | ០% | |

P : តួលេខខែ មេសា ឧសភា និងមិថុនា ឆ្នាំ២០១៤ ជាតួលេខព្យាករដោយ ក.ស.វ. ( តាមវិធីសាស្រ្ត DECOMPOSITION)

ក្រាហ្វ ១១.. ចលនា និងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣ .អត្រាប្តូរប្រាក់

| ប្រភេទ | មីនា ២០១៤ | កុម្ភៈ ២០១៤ | មីនា ២០១៣ | ប្រភេទ | មីនា ២០១៤ | កុម្ភៈ ២០១៤ | មីនា ២០១៣ |
|---|---|---|---|---|---|---|---|
| រ/ដុល្លារ | ៤០១៥រ/១$ | ៣៩៨០រ/១$ | ៣៩៩៥រ/១$ | បាត/ដុល្លារ | ៣២,៥០បាត/១$ | ៣២,៥៧បាត/១$ | ២៩,៣២បាត/១$ |
| រ/បាត | ១២៤រ/១បាត | ១២២រ/១បាត | ១៣៦រ/១បាត | ដុង/ដុល្លារ | ២១០៨៥ដុង/១$ | ២១០៨០ដុង/១$ | ២០៩២០ដុង/១$ |
| រ/ដុង | ០,១៩០រ/១ដុង | ០,១៨៩រ/១ដុង | ០,១៩១រ/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែមីនា ឆ្នាំ២០១៤ ថវិកាជាតិ មានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ៨១៧,៦ពាន់លានរៀល (មធ្យមប្រចាំខែ ៨៧% នៃផែនការ) ក្នុងនោះចំណូលចរន្តចំនួន ៨១៧,២ពាន់លានរៀល (មធ្យមប្រចាំខែ ៩១% នៃផែនការ) និងនិងចំណូលមូលធន ០,៤ពាន់លានរៀល។

- បើធៀបនឹងខែមុនចំណូលថវិកាជាតិ កើនឡើង១២,៧% និងកើនឡើង២១,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។
- នៅក្នុងចំណូលចរន្ត :
  - ✓ ចំណូលសារពើពន្ធមានចំនួន ៧២០,៣ពាន់លានរៀល កើនឡើង៧,៣% ធៀបនឹងខែមុន និងកើនឡើង២២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

ក្រាហ្វ ២.១ ចំណូលថវិកាជាតិ ឆ្នាំ ២០១២–២០១៤ (ពាន់លានរៀល)




  - ✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ៩៦,៩ពាន់លានរៀល កើនឡើង៨២,១% ធៀបនឹងខែមុន និងកើនឡើង១៨,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង២.១ .មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : +៥,៨% | (+២៧,៥%) | ➢ នេសាទ: +៤,៩% | (+១៥២,៨%) |
| ➢ ចំណូលពន្ធដារ : +២៦,១% | (+២០,១%) | ➢ អាកាសចរណ៍ស៊ីវិល : -៧៩% | (-៨០%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: +១០,៦% | (+២៤,៦%) | ➢ ផលទុននៃសកម្មភាពទេសចរណ៍: — | (+១១១%) |
| ✧ កាស៊ីណូ : -៧,៦% | (+៥៨,៤%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : -៦១% | (-៩%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +២៩៦% | (+២៥០៨%) | ➢ អាករស្ពានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): +១៣% | (+៤៩%) |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +៣,៩% | (-២០,៨%) | ➢ ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ ): +៣៧% | (+១៥%) |

២.២. **ចំណាយថវិកាជាតិ** : អនុវត្តបាន ៧១១,៧ពាន់លានរៀល (*មធ្យមប្រចាំខែ ៤៨% នៃផែនការ*) ក្នុងនោះ **ចំណាយចរន្ត** ចំនួន ៥៧៣,៧ពាន់លានរៀល (*មធ្យមប្រចាំខែ ៦៩% នៃផែនការ*) និង**ចំណាយមូលធន** ចំនួន ១៣៧,៩ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** កើនឡើង ១% និងកើនឡើង១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ: ចំណាយចរន្តថយចុះ១២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ២.២០១ ចំណាយថវិកាជាតិ ឆ្នាំ .២ –២០១៤
(ពាន់លានរៀល)




២.៣. សមតុល្យថវិកាជាតិ : *ថវិកាជាតិនៃខែមីនាមានអតិរេក ១០៥,៩ពាន់លានរៀល ស្មើនឹង ២៦,៤លានដុល្លារ ស.រ.អា។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមីនា ឆ្នាំ២០១៤ មានលក្ខណៈដូចខាងក្រោម:

➢ រូបិយវត្ថុ **M** 2 មានចំនួន ៣៥១៦២ពាន់លានរៀល កើនឡើង៣,៨% ធៀបនឹងខែមុន និងកើនឡើង ១៥,៤ %ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **កំណើន $M_2$** ធៀបនឹងខែមុន ជាចម្បងបណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ និងប្រាក់បញ្ញើជារូបិយបណ្ណ។

➢ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ មានចំនួន ១៧,៧ %នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨២,៣%។

ក្រាហ្វ៣១.. សមាសធាតុរូបិយវត្ថុខែមីនា ឆ្នាំ២០១៤




តារាង៣.១ .សមាមាត្រចំនួនប្រាក់រៀល ទៅនឹងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៤

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៧% | ១៨,0% | ១៧,៧% | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣៤%, | ១៣៥%, | ១៣,៨% | | | | | | | | | |

ក្រាហ្វ៣២.. បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែមីនា២០១៤ :ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** (មិនទាន់មានតួលេខ)
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១០៩៧៨ ពាន់លានរៀល ថយចុះ 0,២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៨,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២ .ការផ្តល់ឥណទាន

| ផ្តល់ដោយ | មីនា ២០១៤ | កុម្ភៈ ២០១៤ | មីនា ២០១៣ |
|---|---|---|---|
| ធនាគារពាណិជ្ជ (ពាន់លានរៀល) | ៣២១០០ | ៣១៣៣១ | ២៤៨០០ |
| ក្នុងនោះ ជារៀល | ៤៥២ | ៤៤៤ | ៤១៣ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ពាន់លានរៀល) | មិនទាន់មានតួលេខ | ៥៧៧៧ | ៣៩៨៥ |

តារាង៣.៣ .អត្រាការប្រាក់ប្រចាំឆ្នាំ នៅធនាគាពាណិជ្ជនាខែមីនា

| | | | |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៨៤% | ៥,៨៥% | ៥,៩0% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៥,៩៦% | ១៥,៩៣% | ១១,៨0% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៧% | ៤,២៧% | ៤,៤៤% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,១៨% | ១១,១៧% | ១១,៧២% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមីនាឆ្នាំ២០១៤ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម :

- **កសិកម្ម** :
  - ✓ ផលិតផលនេសាទសម្រេចបាន ៥១,0ពាន់តោន ថយចុះ ២៧% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- **ឧស្សាហកម្ម** :
  - ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣៦៩,១GWh កើនឡើង ១៥% ធៀបនឹងខែមុន និងកើនឡើង ១៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះវារីអគ្គិសនីមានចំនួន ១៥,៧GWh ថយចុះ ៤៣ % ធៀបនឹងខែមុនប៉ុន្តែកើនឡើង ៦២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
  - ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើង មានចំនួន ៥៨៤,៣ លានដុល្លារ កើនឡើង ៣២% ធៀបនឹងខែមុន និងកើនឡើង ៤0% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន —មីនា ២០១៤ | ចំនួន—កុម្ភៈ ២០១៤ | ចំនួន—មីនា ២០១៣ |
|---|---|---|---|
| ▪ រោងចក្រថ្មីដែលបានចុះបញ្ជី | ២៣ | ២០ | ១០ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១១៣៦ | ១១១៣ | ៩៤៤ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៨ | ៨ | ២៣ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | NA | ១ | ១២ |

➢**សំណង់** (ការអនុញ្ញាត) :

✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៥៣៨,៧ពាន់ម² ថយចុះ ៨% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៦៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១៨៩,៦លានដុល្លារ កើនឡើង ១៣% ធៀបនឹងខែមុន និងកើនឡើង ១០៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន :

តារាង៤.២ .សំណង់អនុញ្ញាត**តាមប្រភេទផ្សេងៗ**

| ប្រភេទ | ពាន់ម² –មីនា ២០១៤ | ពាន់ម² –កុម្ភៈ២០១៤ | ពាន់ម² –មីនា ២០១៣ |
|---|---|---|---|
| ▪ លំនៅឋាន | ៤១៦,១ | ១៨៥,៦ | ២០៤,៦ |
| ▪ ឧស្សាហកម្ម | ៣០,៧ | ២៩៣,៧ | ៣៥,៨ |
| ▪ ពាណិជ្ជកម្ម | ៣០,៤ | ៥៨,០ | ៦១,២ |
| … | | | |
| អនុញ្ញាតសរុប | ៥៣៨,៧ | ៥៨៨,៣ | ៣២៦,០ |

✓ ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមជាងគេនាខែនេះគឺ លំនៅឋាន ៧៧% នៃផ្ទៃក្រឡាសរុប ។

➢**ការងារ**

តារាង៤.៣ .**ការទទួលបាន**ការងារ

| ប្រភេទ | នាក់–មីនា២០១៤ | នាក់–កុម្ភៈ២០១៤ | នាក់–មីនា ២០១៣ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | NA | NA | ១២៤៥ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣៤៤៥ | ៣៥៣៥ | ២៦៣១ |
| អ្នកទទួលបានការងារក្នុងប្រទេស | ២២៣៦ | ២៥៣១ | ១១២៨ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១២១៩ | ១០០៤ | ១៥០៣ |

➢ **វិនិយោគ**

តារាង៤.៤. គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មីនា២០១៤ | កុម្ភៈ២០១៤ | មីនា២០១៣ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២២១,៤ | ១០៩,៨ | ២០ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ២៣ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៨៦,១(-) | ៥៣,២ (១៤) | ២០ (០) |
| វិស័យទេសចរណ៍ | ៨៥,៣ | ៣៣,៦ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៥០ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៣ | ១៧ | ៥ |
| បង្កើតការងារ (ពាន់នាក់) | ១៤,៦ | ១៧,១ | ៨ |

➢**សេវាកម្ម និងទេសចរណ៍**

តារាង៤.៥. ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន –មីនា ២០១៤ | ចំនួន – កុម្ភៈ២០១៤ | ចំនួន–មីនា ២០១៣ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣៥៨ | ៣៩៥ | ២២១ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៧ | ៣ | ០ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | .. | ២៦៣ | ៩០ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៧៦៩ពាន់តោន ថយចុះ ៦២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៤.៦. ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: +៣៣% | (+៣%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +៣២% | (+៦៩%) |
| ▪ កំពង់ផែកំពង់សោម: -៧៩% | (+៣៧%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -១៧% | (+១៣៦%) |

តារាង៤.៧. ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៦,៧ | -២% | +៤៩% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៤,០ | -៧% | +១៣% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៧២,៥ | -១០% | +៩% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៧២,៤ | +៦,៦% | +១២,២% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤០០,១ | -៦,០% | +៤,៧% |
| ✓ តាមផ្លូវអាកាស | ២០៤,៤ | -១៥,០% | +៦,២% |
| ✓ តាមផ្លូវគោក និងទឹក | ១៩៥,៦ | +៥,៦% | +៣,១% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ ពីប្រភពអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលនាខែមីនាមានចំនួន ៣០៣៣,២ពាន់លានរៀល (ស្មើនឹង ៧៥៥,៥លានដុល្លារ ស.រ.អា.) កើនឡើង១៦,៦% ធៀបនឹងខែមុន និងកើនឡើង១១,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ ៖

តារាង៥.១. បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១៣,៩% | -១៨,៤% | រថយន្តសរុប (ព.ល.រ) | +២២,២% | +១៨,៥% |
| ប្រេងម៉ាស៊ូត | +២១,៩% | +៣៥,៧% | រថយន្តសរុប (គ្រឿង) | +១៤,៨% | +១៣,១% |
| ឧស្ម័ន | -១៨,៥% | -២៩,៤% | ត្រាក់ទ័រនិងគោយន្ត (គ្រឿង) | +១៤,៦% | +១៩,០% |
| អគ្គិសនីនាំចូល | +២២,៨% | +២,៩% | ម៉ូតូ (គ្រឿង) | +១៧,១% | +២៧,៨% |
| ដែកសំណង់ | +២៨,០% | -១៨,៣% | អង្ករ | -១៤,៨% | -២៥,៣% |
| ស៊ីម៉ង់ត៍ | +១៣,៥% | +៣៣,១% | ផ្លែឈើនិងបន្លែ | +១៧,៦% | +១៧៧,២% |
| គ្រឿងអេឡិចត្រូនិក | +៩,៤% | +៨៧,១% | ជីនិងថ្នាំកសិកម្ម | +៤០,៨% | +៦៥,៧% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៥១,២% | +២២,១% |

➡ **ការនាំចេញ** ខែមីនាឆ្នាំ២០១៤ មានចំនួន ២៦២០,៦ពាន់លានរៀល ស្មើនឹង ៦៥២,៧លានដុល្លារ ស.រ.អា. (៨៦% នៃការនាំចូល) កើនឡើង១,២% ធៀបនឹងខែមុន និងកើនឡើង១៦,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២. បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +៦៧,៥% | +៨១,៧% | ផលិតផលនេសាទ | +២៩,២% | +១៩,៤% |
| វាយនភណ្ឌនិងស្បែកជើង | -៥,៧% | +៨,៦% | កៅស៊ូ | +២៣,៣% | +១១២,០% |
| អង្ករ | +១៣,៦% | -៥,៣% | | | |

➡ ក្នុងខែមីនានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៤១២,៦ពាន់លានរៀល ស្មើនឹង ១០៣លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមីនា ឆ្នាំ២០១៤នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម ៖

**តារាង ៦.១.** សូចនាករសេដ្ឋកិច្ច សង្គមកិច្ច ដែលមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | សំណង់ឧស្សាហកម្ម<br>សំណង់ពាណិជ្ជកម្ម | -៩០%<br>-៤៨% | -១៤%<br>-៥០% | បើនិយាយជារួម វិស័យសំណង់ឆ្នាំ ២០១៤ មានស្ថានភាពល្អប្រសើរ (សរុបបីខែដើមឆ្នាំនេះ ផ្ទៃក្រឡាអនុញ្ញាតឲ្យសាងសង់ស្មើនឹង៣៤% នៃតួលេខសរុបឆ្នាំ២០១៣)។ |
| ២ | ការនាំចូលផ្លែឈើ និងបន្លែ | +១៧,៦% | +១៧៧,២% | — |
| ៣ | ការនាំចូលបារី | -៩៤,៦% | -៨១,៧% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម :

១) ការឡើងថ្លៃទំនិញនៃ **ក្រុមការសិក្សា** និង**សុខាភិបាល** ដែលជាបញ្ហាសង្គមកិច្ចដ៏សំខាន់ពីរ គួរត្រូវបានយកមកគិតគូរពិចារណា។

ក. ការសិក្សារបស់សិស្ស-និស្សិតលក្ខណៈទូលំទូលាយ គ្រប់ស្រទាប់វណ្ណៈ គឺជាចលករនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា។ ការឡើងថ្លៃនៃក្រុមការសិក្សា ជាបញ្ហាសម្រាប់ជីវភាពរស់នៅ ការចូលសិក្សា និងការបន្តសិក្សារបស់សិស្ស-និស្សិត នៃគ្រួសារមធ្យមនិងក្រីក្រ។

ខ. តម្លៃខ្ពស់នៃសុខាភិបាលនៅកម្ពុជា ធ្វើឲ្យភាពប្រកួតប្រជែងនៃវិស័យនេះថយចុះ និងការធ្វើដំណើររបស់ប្រជាជនកម្ពុជាទៅព្យាបាលនៅប្រទេសជិតខាងកើនឡើង។

២) ការអប់រំប្រកបដោយគុណភាព និងស្របតាមបទដ្ឋានអប់រំ ជាកត្តាចាំបាច់ក្នុងការលើកកម្ពស់គុណវុឌ្ឍ សមត្ថភាព និងសិលធម៌នៃធនធានមនុស្សកម្ពុជា ជាពិសេសសម្រាប់ការបណ្តុះបណ្តាលនៅកម្រិតឧត្តមសិក្សា ទាំងនៅគ្រឹះស្ថានរដ្ឋ ទាំងឯកជន។ កន្លងមកថ្មីៗនេះ មានករណីដែលគ្រឹះស្ថានសាធារណៈរដ្ឋបាល (ដូចជា**សាកលវិទ្យាល័យជាតិគ្រប់គ្រង**) បានធ្វើការបែងចែកម៉ោងបង្រៀនច្រើនហួសហេតុដល់គ្រូក្របខ័ណ្ឌ មិនស្របតាមបញ្ញត្តិគរុកោសល្យ (ប្រកាសលេខ ១៤៣៥ ប្រការ ២៦ របស់ក្រសួងអប់រំ) ដែលកំណត់អំពីចំនួនម៉ោងអតិបរមាសម្រាប់គ្រូបង្រៀនម្នាក់ៗ ត្រឹម ២៤ម៉ោង ស្មើនឹង៨ ថ្នាក់។ **ក.ស.វ.** យល់ឃើញថា ស្ថានការណ៍នេះនឹងបង្កើតផលវិបាកសង្គមដូចខាងក្រោម :

ក. ករណីនេះ ជាឧទាហរណ៍អំពីភាពធូររលុងនៃការអនុវត្តច្បាប់របស់ស្ថាប័នសាធារណៈដែលគួរតែដើរតួជាគំរូដល់ វិស័យឯកជន។

ខ. គ្រូដែលទទួលបន្ទុកបង្រៀនច្រើនពេក ពុំមានពេលវេលា និងកម្លាំងកាយចិត្តសម្រាប់ បង្រៀនឲ្យបានល្អ និងកិច្ចការស្រាវជ្រាវ ដើម្បីពង្រីក និងធ្វើបច្ចុប្បន្នកម្មចំណេះដឹងទេ។

គ. គុណភាពអប់រំនឹងរងការប៉ះពាល់ជាដំណំ ។ ក្នុងដំណើរការសកលភាវូបនីយកម្ម ជាពិសេសក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននាពេលដ៏ខ្លីខាងមុខ នឹងមានលំហូរដោយសេរីនៃទំនិញ សេវាកម្ម វិនិយោគ និងពលកម្ម។ ក្នុងលក្ខណ្ឌថ្មីនៃការប្រកួតជែងផង និងសហប្រតិបត្តការផងជាមួយបណ្តាប្រទេសអាស៊ាន ពលករកម្ពុជាអាចពិបាកប្រកួតជាមួយពលករបរទេស ក្នុងការទទួលការងារ ជាពិសេសការងារដែលមានជំនាញខ្ពស់ និងប្រាក់កម្រៃច្រើន ទោះក្នុងប្រទេស របស់ខ្លួនក្តី ឬក្រៅប្រទេសក្តី ។ ដូច្នេះ ការកសាងធនធានមនុស្ស តាមរយៈការអប់រំកម្រិតឧត្តមសិក្សា ដើរតួយ៉ាងសំខាន់ក្នុងការកសាងភាពប្រកួតប្រជែងរបស់ពួកគេ ក៏ដូចជារបស់ប្រទេសជាតិទាំងមូល។

ឃ. អ្នកវិទ្យាសាស្រ្តជាច្រើន ដែលក្នុងនោះ មួយចំនួនធំជាមន្ត្រីរាជការ ដែលមានសញ្ញាបត្រ និងសមត្ថភាពខ្ពស់ អាចចែករំលែកចំណេះដឹងដល់និស្សិតខ្មែរត្រូវបានផាត់ចោល។ ម្យ៉ាងវិញទៀត ការឆ្លៀតបង្រៀនក្រៅម៉ោងរបស់ពួកគេជាមធ្យោបាយតែមួយគត់ ដែលអាចទទួលបានកម្រៃខ្លះៗ សម្រាប់ប៉ះប៉ូវជីវភាពរស់នៅ និងបន្តការងារក្នុងស្ថាប័នរបស់ខ្លួន។

ង. វិសមភាពនៃប្រាក់ចំណូលរបស់បុគ្គលិក មន្ត្រីរាជការដូចគ្នា ជាបញ្ហាសមធម៌សង្គម ដែលធ្វើឲ្យខូចសតិអារម្មណ៍របស់បញ្ញវន្តខ្មែរមួយចំនួនធំ ដែលមិនមែនជាគ្រូក្របខ័ណ្ឌក្នុងសាកលវិទ្យាល័យ ប៉ុន្តែជីវភាពរបស់ពួកគេសង្ឃឹមលើការបង្រៀនក្រៅម៉ោង។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី
## ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
## ប្រចាំខែមេសា ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៤/១៤<br>ម៉ោង ៩:០០នាទី | ដឹកនាំកិច្ចប្រជុំការងារផ្ទៃក្នុងរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៣/០៤/១៤<br>ម៉ោង១០:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ផេង សុទិដ្ឋានោ** ដើម្បីត្រៀមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋ មន្ត្រី។ |
| ៣ | ០៣/០៤/១៤<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៧/០៤/១៤<br>ម៉ោង ០៩:០០នាទី | ប្រជុំគណៈកម្មការស្ដីពីការកែសម្រួលគម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ៦ ចាប់ពីស្តូបសណ្ឋាគារសុខាអង្គរ ដល់អាកាសយានដ្ឋានយោធាខេត្តសៀមរាប នៅសាលាខេត្តសៀមរាប។ |
| ៥ | ០៧/០៤/១៤<br>ម៉ោង ១៦:០០នាទី | ចូលរួមជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យឯកឧត្តម **Anil Wadhwa** អនុរដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋឥណ្ឌា ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី ខេត្តសៀមរាប។ |
| ៦ | ០៧/០៤/១៤<br>ម៉ោង ១៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសារមន្ទីរ ខេត្តសៀមរាប។ |
| ៧ | ០៨/០៤/១៤<br>ម៉ោង ១៦:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ។<br>២-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ០៩/០៤/១៤<br>ម៉ោង ០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ។<br>២-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។<br>៣-បញ្ហាផ្សេងៗ៖<br>៣.១-សន្ធិសញ្ញាស្ដីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។<br>៣.២-កិច្ចព្រមព្រៀងស្ដីពីការជួយគ្នាទៅវិញទៅមក ផ្នែកយុត្តិធម៌ក្នុងវិស័យរដ្ឋប្បវេណីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។<br>នៅទីស្ដីការ គណៈរដ្ឋមន្ត្រី។ |
| ៩ | ១០/០៤/១៤<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់វិញ្ញាបនបត្រ បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់សិក្ខាកាម និងនិស្សិត**សាកលវិទ្យាល័យធនធានមនុស្ស** ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី
## ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
## ប្រចាំខែមេសា ឆ្នាំ២០១៤ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១០ | ១០/០៤/១៤<br>ម៉ោង ១៥:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចម្រើនព្រះបរិត្ត និងសម្តែងព្រះធម្មវិសេសទេសនាក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១១/០៤/១៤<br>ម៉ោង ០៨:៣០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅខេត្តតាកែវ។ |
| ១២ | ១៧/០៤/១៤<br>ម៉ោង ០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញា។<br>៤-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៨/០៤/១៤<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញា។<br>៤-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើពិធីសារ នៃវិសោធនកម្មលើអនុសញ្ញាអន្តរជាតិស្តីពី សាមញ្ញកម្ម និងការធ្វើឲ្យស៊ីចង្វាក់នៃនីតិវិធីគយ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៤ | ២២/០៤/១៤<br>ម៉ោង ១៥:០០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឲ្យប្រធានសហព័ន្ធអ្នកពិភពលោក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២៤/០៤/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៥/០៤/១៤<br>ម៉ោង ១១:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **សយ សុខាន់** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២៨/០៤/១៤<br>ម៉ោង ០៨:៣០នាទី | ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបើកសន្និសីទអន្តរជាតិ ក្រោមប្រធានបទ "**ការអភិវឌ្ឍសេដ្ឋកិច្ច និងវិស័យអប់រំអ៊ីស្លាម**" នៅសណ្ឋាគារភ្នំពេញ។ |
| ១៨ | ២៨/០៤/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បានជួបពិភាក្សាការងារជាមួយ លោក Krisan ILYUMZHINOV ប្រធានសហពន្ធ័អុកពិភពលោក

កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី បានជួបពិភាក្សាការងារជាមួយ លោក Krisan ILYUMZHINOV ប្រធានសហពន្ធ័អុកពិភពលោក និងជាអតីតប្រធានាធិបតីនៃសាធារណរដ្ឋកាល់មីកគី ដោយមានការអញ្ជើញចូលរួមពីសំណាក់ លោក Berik BALGABAEV នាយកការយាល័យសហព័ន្ធអុកនៅរុស្ស៊ី លោកស្រី Galina Goryachkina លេខាទី១ទូតរុស្ស៊ី មន្ត្រីនៃឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំនៅកម្ពុជា អនុប្រធាននិងសមាជិក ECOSOCC និងតំណាងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី សុខ អាន។



ភាគីរុស្ស៊ីស្នើសុំឲ្យភាគីកម្ពុជាជួយបោះឆ្នោតគាំទ្របេក្ខភាពលោក Krisan ILYUMZHINOV ជាប្រធានសហពន្ធ័អុកពិភពលោកជាថ្មីម្ដងទៀត ហើយបានសន្យាជួយឧបត្ថម្ភវិស័យអុកដល់កម្ពុជា ព្រមទាំងផ្ដល់អាហារូបករណ៍ដល់ប្រជាជនកម្ពុជា ដែលមានបំណងសិក្សាផ្នែកអុកនៅរុស្ស៊ី។

ជាចុងក្រោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា បានស្នើឲ្យ លោក Krisan ILYUMZHINOV ជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដល់អុកប្រពៃណីកម្ពុជា និងនាំសំណើរបស់ភាគីរុស្ស៊ី ជម្រាបជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ដើម្បីសម្រេចដ៏ខ្ពង់ខ្ពស់។

# ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបើកសន្និសីទអន្តរជាតិស្តីពី ការអភិវឌ្ឍវិស័យអប់រំអ៊ីស្លាមនិងសេដ្ឋកិច្ច

កាលពីថ្ងៃទី២៨ខែមេសាឆ្នាំ២០១៤ ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ធ្វើជាអធិបតីក្នុងពិធីបើកសន្និសីទអន្តរជាតិក្រោមប្រធានបទ"**ការអភិវឌ្ឍវិស័យអប់រំអ៊ីស្លាមនិងសេដ្ឋកិច្ច**" ដែលរៀបចំដោយអង្គការក្រុមប្រឹក្សាអ៊ីស្លាមអភិវឌ្ឍន៍កម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី និងតំណាងសហគមន៍អ៊ីស្លាមជាតិនិងអន្តរជាតិ។

ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តម យឹម ណុលឡា បានកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះ គណៈដឹកនាំគ្រប់លំដាប់ថ្នាក់នៃសាសនាអ៊ីស្លាម ដែលបាននខិតខំប្រឹងប្រែងដឹកនាំកិច្ចការសាសនាអ៊ីស្លាម និងសហគមន៍សាសនិកអ៊ីស្លាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅកសាងទំនាក់ទំនងកាន់តែប្រសើរក្នុងរង្វង់ផ្ទៃក្នុងសាសនាអ៊ីស្លាមទាំងក្នុងនិងក្រៅប្រទេស ក៏ដូចជាជាមួយសាសនាដទៃ ដើម្បីសុខដុមនីយកម្ម និងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែប្រសើរឡើងថែមទៀត។ ជាក់ស្តែង តាមរយៈអង្គការក្រុមប្រឹក្សាអ៊ីស្លាមអភិវឌ្ឍន៍កម្ពុជាបងប្អូនខ្មែរអ៊ីស្លាមបាននចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចការសង្គមនិងមនុស្សធម៌ ការលើកកម្ពស់វិស័យអប់រំសាសនាអ៊ីស្លាម ការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍសហគមន៍អ៊ីស្លាម ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍និងជំនឿរបស់បងប្អូនខ្មែរអ៊ីស្លាម ស្របតាមច្បាប់និងបទប្បញ្ញត្តិនានារបស់កម្ពុជា សំដៅលើកកម្ពស់ជីវភាពរស់នៅនិងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

សន្និសីទនេះគឺជាវេទិកាសម្រាប់ផ្លាស់ប្តូរបទពិសោធន៍និងការអនុវត្តល្អៗ សំដៅធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រសិទ្ធិភាពនៃការអប់រំផ្នែកសាសនាអ៊ីស្លាមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដើម្បីចូលរួមចំណែកក្នុង

ការធានាឱ្យបាននូវសង្គមមួយដែលមានសុខសន្តិភាពសុខដុមរមនា និងវិបុលភាព។ អាស្រ័យដោយនយោបាយ**ឈ្នះ-ឈ្នះ**ដែលជាគំនិតផ្តួចផ្តើមដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា យើងទទួលបាននូវសុខសន្តិភាព និងស្ថេរភាពនយោបាយពេញលេញនៅទូទាំងប្រទេស ដែលនេះជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។

ជាក់ស្តែង បងប្អូនខ្មែរអ៊ីស្លាមទាំងអស់សុទ្ធតែមានសិទ្ធិសេរីភាពពេញលេញក្នុងការគោរពប្រតិបត្តិតាមជំនឿសាសនារបស់ខ្លួន ដូចជាសិទ្ធិពាក់ហ៊ីចាប់(កន្សែងគ្របក្បាល) តាមប្រពៃណីសាសនាអ៊ីស្លាម នៅតាមទីសាធារណៈ សិទ្ធិសំពះយ៉ាំង(ថ្វាយបង្គំ) សិទ្ធិប្រារព្ធពិធីសូត្រគម្ពីរគួរអានជាលក្ខណៈជាតិនិងអន្តរជាតិ និងសិទ្ធិប្រារព្ធពិធីបុណ្យទានផ្សេងៗតាមប្រពៃណីសាសនាអ៊ីស្លាម។ រាជរដ្ឋាភិបាល បើកទូលាយឱ្យបងប្អូនខ្មែរអ៊ីស្លាមអាចកសាងហេដ្ឋារចនាសម្ព័ន្ធនានាដើម្បីទ្រទ្រង់ជីវភាពសង្គម និងផ្តល់នូវភាពងាយស្រួលក្នុងការគោរពប្រតិបត្តិតាមជំនឿសាសនារបស់ខ្លួន ក៏ដូចជាការសិក្សារៀនសូត្រជាដើម។ បច្ចុប្បន្ននៅកម្ពុជាយើងមានវិហារអ៊ីស្លាមប្រមាណ ៤០០ ស៊ូរ៉ាវចំនួនជាង ៤០០ និងសាលារៀនមានចំនួនជាង ២០០ ហើយចំនួនទួន(គ្រូបង្រៀនសាសនា) ក៏បានកើនឡើងជាច្រើនផងដែរ។លើសពីនេះទៀតនិស្សិតខ្មែរអ៊ីស្លាមជាច្រើននាក់ បានបន្តការសិក្សានៅកម្រិតឧត្តមសិក្សាទាំងក្នុងនិងក្រៅប្រទេស។

ជាចុងក្រោយ ឯកឧត្តម យឹម ណុលឡា មានជំនឿយ៉ាងមុតមាំថា សន្និសីទនេះនឹងនាំមកនូវលទ្ធផលល្អៗជាច្រើនដោយមានការចូលរួមយ៉ាងសកម្មពីវាគ្មិននានា ដែលនឹងចែករំលែកនូវបទពិសោធន៍ ចំណេះដឹង និងការអនុវត្តល្អៗ តាមជំនាញរៀងៗខ្លួន ដើម្បីជាផលប្រយោជន៍ទៅវិញទៅមករបស់ជាតិមាតុភូមិជាទីស្នេហានៃយើង។

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ង៉ាន់ ភិរុណ | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង វត្ថមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ផារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត កក្កដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in